ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

……សហវ……

ថ្ងៃទី ១៤ ខែ មីនា ឆ្នាំ 2008

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៨

# សេចក្តីណែនាំ

## ស្តីពី

## ការធ្វើសមាហរណកម្ម បំណុលពន្ធ និង មិនមែនសារពើពន្ធ

យោងប្រកាសលេខ ១.៤០២ .ចុះថ្ងៃទី ២៩ ខែ. ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់អោយប្រើប្រាស់ប្លង់គណនេយ្យរដ្ឋ ។

នៅឆ្នាំដំបូងនៃការអនុវត្តន៍ប្លង់គណនេយ្យថ្មីដែលជាប្រភេទប្លង់គណនេយ្យបង្គរ និងដើម្បីអោយមានលក្ខណៈងាយលើការធ្វើសមាហរណកម្មបំណុលពន្ធ បំណុលមិនមែនសារពើពន្ធដែលត្រូវទារ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមចេញនូវសេចក្តីណែនាំអនុវត្តដូចខាងក្រោម :

១- នៅចុងការិយបរិច្ឆេទ ២០០៧ នាយកដ្ឋានពន្ធដារ ទីចាត់ការគយ និងរដ្ឋាករ និង នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវផ្ញើរបាយការណ៍តួលេខសរុប នៃបំណុលពន្ធ និងបំណុលមិនមែនសារពើពន្ធដែលត្រូវទារពីក្រុមហ៊ុន សហគ្រាស អាជីវករ និងពីអង្គភាពនានាដោយគិតនៅចុងថ្ងៃទី ៣១ ខែ ធ្នូ នៃឆ្នាំ ២០០៧ ទៅអោយរតនាគារជាតិដើម្បីកត់ត្រាទៅក្នុងលេខនាគណនេយ្យរដ្ឋ ។ តួលេខបំណុលត្រូវទារត្រូវចែកជាបំណុលរបស់ឆ្នាំ ២០០៧ និង បំណុលរបស់ឆ្នាំមុនៗ។

២-យោងតាមរបាយការណ៍តួលេខបំណុល រតនាគារជាតិត្រូវធ្វើការកត់ត្រានៅក្នុងលេខនាគណនេយ្យខាងឥណពន្ធ នៃគណនី អ្នកជាប់ពន្ធ (លេខ ៤១១ .៤១២ )និង ខាងឥណទាន នៃ គណនី ចំណូលត្រូវប្រមូលបានកត់ត្រាទុកមុន (លេខ ៤៨២ ) ។ តួលេខបំណុលពន្ធ និងមិនមែនសារពើពន្ធ នឹងត្រូវបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលរៀបចំឡើងដោយ រតនាគារជាតិនៅដំណាច់ឆ្នាំ ២០០៧ ។

៣- នៅដើមការិយបរិច្ឆេទបន្ទាប់ រតនាគារជាតិត្រូវធ្វើប្រតិក្រាន្តលេខនាដែលបានកត់ត្រានៅចុងការិយបរិច្ឆេទមុនដោយកត់ត្រា ខាងឥណពន្ធ នៃ គណនី ចំណូលត្រូវប្រមូលបានកត់ត្រាទុកមុន (លេខ ៤៨២ ) និង ខាងឥណទាន នៃគណនី អ្នកជាប់ពន្ធ (លេខ ៤១១ ៤១២ ) ។

៤-នៅពេលដែលប្រមូលចំណូលបំណុលពន្ធ និងមិនមែនសារពើពន្ធបាន នាយកដ្ឋានពន្ធដារ ទីចាត់ការគយនិងរដ្ឋាករ និងនាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ត្រូវធ្វើការកត់ត្រាតាមដានផ្ទៃក្នុងដោយបន្ថយបំណុលត្រូវទារ ។

ទទួលបានសេចក្តីណែនាំនេះ សូមឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជានាយកទីចាត់ការគយ និងរដ្ឋាករ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរតនាគារជាតិ លោកប្រធាននាយកដ្ឋានពន្ធដារ និងលោកប្រធាននាយកដ្ឋានចំណូលមិនមែនសារពើពន្ធ ចាត់តាំងការអនុវត្តន៍អោយទទួលបានលទ្ធផលល្អប្រសើរ ។

រដ្ឋមន្ត្រី

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ចំលងជូន

- នាយកដ្ឋានថវិកា
- លេខាធិការដ្ឋាននៃគណៈកម្មាធិការកែទំរង់ហិរញ្ញវត្ថុសាធារណៈ
  "ដើម្បីជ្រាប"
- ឯកសារ- កាលប្បវត្តិ